# រឿងសត្វមៀម

( ចាក អ. ចូ. )
ជ្រះថ្លាចំពោះព្រះពុទ្ធ តែងរួចចាកទុក្ខសព្វយ៉ាង )

សេច ក្ដីដំណាលថា ព្រះដ៏មានព្រះភាគ ទ្រង់គង់អាស្រ័យក្នុង ឥន្ទសាលគុហានាវេទីយកបព៌ត ។ គ្រានោះមានសត្វមៀមមួយ ពេលព្រះសាស្ដា ស្ដេចយាងទៅបិណ្ឌបាត តែងហើរតាមពាក់កណ្ដាលផ្លូវ លុះព្រះអង្គត្រលប់មកវិញ ក៏នៅទទួលពាក់កណ្ដាលផ្លូវ ជារៀងរាល់ថ្ងៃដែរ ។

ថ្ងៃមួយ សត្វមៀមចុះពីភ្នំ មកថ្វាយបង្គំ ព្រះសម្មាសម្ពុទ្ធ ដែលប្រថាប់កណ្ដាល ប្រជុំព្រះភិក្ខុសង្ឃ ក្នុងសាយណ្ហសម័យ ហើយសំរូលស្លាប ផ្គងអញ្ជលី បន្ទាបក្បាលឈរនមស្សការព្រះទសពល ។

ព្រះអង្គឃើញហើយ ក៏ទ្រង់ញញឹម ។ ព្រះអានន្ទត្ថេរ ទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គទ្រង់ញញឹម តើមានហេតុអ្វី ? ម្នាលអានន្ទ អ្នកចូរមើល សត្វមៀមនេះ ញ៉ាំងចិត្តឱ្យជ្រះថ្លា ក្នុងតថគត និងភិក្ខុសង្ឃ អន្ទោលទៅក្នុងទេវលោក និងមនុស្សលោក អស់មួយសែនកប្ប នឹងបានជាព្រះបច្ចេកពុទ្ធ មួយអង្គនាម សោមនស្ស ។ ពួករុក្ខទេវតាបានពោលថា ឱ្យសព្វសាធុការព្រម ៗ គ្នាថា ៖

ឧលូក មណ្ឌលក្ខិក
វេទិយកេ មំរទិយវាសិក
សុខិតោសិ ត្វំ អយ្យ កោសិយ
កាលុដ្ឋិតំ បស្សសិ ពុទ្ធវំ ។

ហៃមៀម កោសីភ្នែកមូលម្ចាស់អើយ អ្នកនៅយូរហើយលើបព្វតា នាមវេទិយកៈដល់នូវសុខា ឃើញពុទ្ធវរា ក្រោកក្នុងកាលគួរ ។

មៀមនេះចុះចាកទេវលោក គឺកុសលមូលដាស់តឿនហើយ នឹងបានជាព្រះបច្ចេកពុទ្ធមានវិស្សុតនាមថា សោមនស្ស មានញាណគ្មានទីបំផុត ។

សូមអស់លោកអ្នកអនុមោទនា !ចប់